ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦

នៅក្នុងខែមករា ឆ្នាំ២០២៦ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារនីតិកម្ម រួមមាន៖**

  ❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៣លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដើម្បី៖

  ១- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

  ២- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី៖

  - ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពី ការដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន។
  - ការអនុម័តយល់ព្រមលើពិធីសារទី៣ស្តីពី ការពង្រីកសិទ្ធិហោះហើរទី៥រវាងភាគីចុះកិច្ចព្រមព្រៀង ក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាល

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និង

- ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី សេវាកម្ម។

៣- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ។

៤- ពិនិត្យ និងសម្រេចអំពីនីតិវិធីបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ និង

៥- ផ្សេងៗ។

❖ បើកសម័យប្រជុំលើកទី៤ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់ ដូចខាងលើ និងប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី និងបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា នីតិកាលទី៥ និង

❖ ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព) លើកទី៥ អាណត្តិទី៤ នៅអង្គភាពប្រឆាំងអំពើពុករលួយ។

## ២-មុខងារតំណាង

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញពិនិត្យវឌ្ឍនភាពនៃការសាងសង់អគារថ្មីនៃព្រឹទ្ធសភា។
  - បានអញ្ជើញជាអធិបតីក្នុងពិធីក្រុង៣លី និងចម្រើនព្រះបរិត្តឡើងអគារវិមានសាមគ្គីភាព និង
  - បន្តតាមដាន និងផ្តល់យោបល់អំពីការវិវត្តសភាពការណ៍នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **បេសកកម្មក្នុងប្រទេស៖** បានអញ្ជើញចុះសាកសួរសុខទុក្ខ និងនាំយកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ចែកជូនប្រជាពលរដ្ឋភៀសសឹក និងគ្រួសារវីរយុទ្ធជន ចំនួន ៣៥៣គ្រួសារ ព្រមទាំងសិស្សានុសិស្សភៀសសឹក ចំនួន២៩៤នាក់ នៅក្នុងបរិវេណសួនច្បារទល់មុខសាលាស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញចូលរួមពិធីក្រុងពាលី និងចម្រើនព្រះបរិត្ត សូត្រមន្ត ឡើងអគារថ្មី វិមានសាមគ្គីភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** នៅវិមានព្រឹទ្ធសភា។
  - បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា **ស៊ន់ គា** ម្តាយបង្កើតរបស់ **ឯកឧត្តម ទុយ រី** នាយកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា នៅក្រុងសួង ខេត្តត្បូងឃ្មុំ និង
  - បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា **ធិន ធឹង** ម្តាយបង្កើតរបស់ **ឯកឧត្តម ឡោ ចាន់លី** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សខេត្តកំពង់ចាម ស្រុកបាធាយ ខេត្តកំពង់ចាម។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខង្សុនា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖**
  - បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយទីប្រឹក្សា ថ្នាក់ដឹកនាំ និងសមាជិកខុទ្ទកាល័យប្រចាំខែធ្នូ ឆ្នាំ២០២៥ និងកំណត់ទិសដៅការងារសម្រាប់ឆ្នាំ២០២៦ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយទីប្រឹក្សា ថ្នាក់ដឹកនាំ និងសមាជិកខុទ្ទកាល័យប្រចាំខែមករា និងកំណត់ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦ នៅសាលប្រជុំខុទ្ទកាល័យ។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែ ជាមួយប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីពិភាក្សាអំពីការចុះបេសកកម្មរបស់គណៈកម្មការទាំង១០ និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ នៅចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥ និងការជួយគាំទ្រដល់ជនភៀសសឹក នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
  - បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំដើម្បីផ្សារភ្ជាប់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃព្រឹទ្ធសភា (គណៈកម្មការទី២) ជាមួយសាកលវិទ្យាល័យជាតិគ្រប់គ្រង ដោយបានជំរុញឱ្យមានការគាំទ្រ និងកិច្ចសហប្រតិបត្តិការស្រាវជ្រាវលើការស្តារសេដ្ឋកិច្ចព្រំដែន នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- **សកម្មភាពចុះមូលដ្ឋាន៖**
    - បានអញ្ជើញចុះទស្សនកិច្ចសិក្សាឈ្វេងយល់ពីខ្សែចង្វាក់ផលិតកម្ម និងបច្ចេកវិទ្យាឧស្សាហកម្មនៅសួនឧស្សាហកម្ម Samanea នៅស្រុកអង្គស្នួល ខេត្តកណ្ដាល។
    - បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ថ្នាក់ដឹកនាំខេត្ត និងសប្បុរសជន ចុះសួរសុខទុក្ខវីរកងទ័ព ព្រមទាំងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ រួមមាន អង្ករ ទឹកដោះចន្ទី ដំណាប់ចេក ដំណាប់ស្វាយ ទឹកសុទ្ធ អាហារកញ្ចប់ នំខ្មែរ មីជាតិ ថ្នាំពេទ្យ សម្លៀកបំពាក់ និងសម្ភារប្រើប្រាស់មួយចំនួនទៀត ជូនវីរកងទ័ពក្នុងកងពលអន្តរាគមន៍លេខ៧ លេខ៩ និងសឹករងខេត្តនៃខេត្តព្រះវិហារ និង
    - បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាល ជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធសរុប ចំនួន២៩៥នាក់ មកពីទូទាំងសង្កាត់នៃខណ្ឌបឹងកេងកង ខណ្ឌដូនពេញ ខណ្ឌចំការមន រាជធានីភ្នំពេញ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
    - បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាស្តីពី "ការជំរុញការវិនិយោគលើវិស័យកាហ្វេ និងការចែករំលែកបច្ចេកទេសដាំ និងការកែច្នៃកាហ្វេ" នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។
    - បានអញ្ជើញធ្វើបាឋកថាស្តីពី "ឱកាសនៃការកែច្នៃអាហារ" ជូនដល់សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
    - បានអញ្ជើញពិនិត្យការរៀបចំទីកន្លែងបំពេញការងារ នៅអគារថ្មីនៃព្រឹទ្ធសភា ដែលគ្រោងនឹងសម្ពោធដាក់ឱ្យប្រើប្រាស់នាពេលខាងមុខ។
    - បានអញ្ជើញចូលរួមការងារស្ម័គ្រចិត្ត ជាមួយក្រុមការងារស្ម័គ្រចិត្តរបស់ក្រុមហ៊ុនខនហ្វីរេល និងប៉េប៉េអឹម ក្នុងការផលិត និងវេចខ្ចប់នំជំនួសបាយ ដើម្បីត្រៀមទុកចែកជូនវីរកងទ័ព និងបងប្អូនជនភៀសសឹករបស់យើង។
    - បានអញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់៧ថ្ងៃ **អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ឱី សានឿន** ម្តាយបង្កើតរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ជូ វិជិត្ត** រដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅវត្តបទុមវតីរាជវរារាម រាជធានីភ្នំពេញ និង
    - បានអញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធ **មហាឧបាសក គង់ ខាត់** ក្នុងទិវាគម្រប់ខួប៨ឆ្នាំនៃការទទួលមរណភាពរបស់ មហាឧបាសក និងធ្វើបទនមស្ការ សមាទានសីល ចម្រើនព្រះបរិត្ត និងវេរភត្តាហារ និងទេយ្យវត្ថុ ប្រគេនព្រះសង្ឃ នៅវត្តសុវណ្ណគីរី (ជើងធ្នុក) ស្រុកបាធាយ ខេត្តកំពង់ចាម។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញយាងអម **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរព

សក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គទាំងទ្វេសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានកងទ័ពទាំង១៨រូប ដែលបាននិវត្តន៍មកកាន់មាតុប្រទេសវិញ ចូលក្រាបថ្វាយបង្គំគាល់ នៅព្រះរាជដំណាក់សិរីមង្គល ព្រះបរមរាជវាំង។

- បានអញ្ជើញចុះសាកសួរសុខទុក្ខ និងនាំយកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ចែកជូនប្រជាពលរដ្ឋភៀសសឹក និងគ្រួសារវីរយុទ្ធជន ព្រមទាំងសិស្សានុសិស្សភៀសសឹក ដឹកនាំដោយ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នៅក្នុងបរិវេណសួនច្បារទល់មុខសាលាស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។
- បានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នាំយកអំណោយ និងថវិការបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជូនវីរយុទ្ធជន ដែលកំពុងសម្រាកព្យាបាល នៅតាមមន្ទីរពេទ្យនានា ក្នុងរាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **លោកជំទាវនាយឧត្តមសេនីយ៍ ម៉ី មនដារី** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី ការងារស្រាវជ្រាវអំពីសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ព្រំដែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយចែកជូនប្រជាពលរដ្ឋភៀសសឹក ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង។
- បានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំគណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា។
- បានអញ្ជើញអមដំណើរ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចូលរួមជាមួយក្រុមការងារស្ម័គ្រចិត្តជួយរៀបចំវេចខ្ចប់អំណោយជាគ្រឿងឧបភោគ បរិភោគ និងសម្ភារប្រើប្រាស់ចាំបាច់សម្រាប់ចែកជូនប្រជាពលរដ្ឋភៀសសឹកនៅតាមជំរំសុវត្ថិភាព នៅស្ថានីយទូរទស្សន៍បាយ័ន រាជធានីភ្នំពេញ។
- បានអញ្ជើញអមដំណើរ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ជាគ្រឿងឧបភោគ បរិភោគ សម្ភារប្រើប្រាស់ និងថវិកា ផ្តល់ជូនវីរយុទ្ធជនកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យ ចំនួន៥ ក្នុងរាជធានីភ្នំពេញ។
- បានអញ្ជើញចុះជួបសួរសុខទុក្ខ និងនាំយកព្រះរាជអំណោយ ជាគ្រឿងឧបភោគ បរិភោគ

សម្ភារប្រើប្រាស់ ព្រមទាំងថវិកា ប្រគល់ជូនវីរកងទ័ពប្រចាំសមរភូមិមុខ និងវីរកងទ័ពដែលសម្រាកព្យាបាល នៅខេត្តកំពង់ធំ និងខេត្តព្រះវិហារ។

- បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកស្បៀងចែកជូនជនភៀសសឹក ចំនួន១,១៨០គ្រួសារ នៅមណ្ឌលសុវត្ថិភាពវត្តកំពង់សង្កែ ខេត្តព្រះវិហារ។
- បានអញ្ជើញជួបសួរសុខទុក្ខ និងនាំយកអំណោយផ្តល់ជូននាយទាហាន នាយទាហានរង និងពលទាហានកងពលតូចអន្តរាគមន៍លេខ៩ និងវីរកងទ័ពដែលកំពុងសម្រាកព្យាបាលរបួសនៅមណ្ឌលសុខភាពគូលេន ស្រុកគូលេន និងមន្ទីរពេទ្យបង្អែក ១៦ មករា ក្រុងព្រះវិហារ ខេត្តព្រះវិហារ និង

- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ និងជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ សន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា **ចំនួន១៥៥លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន៧៩លើក**។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន៥លើក។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម ខេង សិទ្ធិគុណ** បានអញ្ជើញសួរសុខទុក្ខ **ឯកឧត្តម ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ដែលកំពុងសម្រាកថែទាំសុខភាព នៅមន្ទីរពេទ្យជប៉ុនសាន់រ៉ាយស៍ភ្នំពេញ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា៖

- តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រួមមាន គ្រឿងឧបភោគ បរិភោគ សម្ភារប្រើប្រាស់ និងថវិកា ប្រគល់ជូនរដ្ឋបាលសង្កាត់ព្រែកតាសេក ដើម្បីឧបត្ថម្ភដល់វីរកងទ័ពជួរមុខ និងប្រជាពលរដ្ឋភៀសសឹក នៅសាលាសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
- បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន១១លើក។

- ❖ **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗ របស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៩លើក។
- ❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗ របស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៥លើក និង
- ❖ **ឯកឧត្តម ឱ បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២លើក។

- បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសាវតាររបស់ព្រឹទ្ធសភា ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ចំនួន១៥០នាក់ និង
- បានទទួលពាក្យបណ្តឹង ចំនួន៨បណ្តឹង រំលឹកជម្រុញការដោះស្រាយពាក្យបណ្តឹង ចំនួន៤បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន១០បណ្តឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូន សម្តេចតេជោប្រធានព្រឹទ្ធសភា ពីលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹងរបស់គណៈកម្មការទី១ព្រឹទ្ធសភា ចំនួន៣បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធ ចំនួន៣បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន២បណ្តឹង។

## ៣-មុខងារសហប្រតិបត្តិការអន្តរជាតិ

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**
  - ❖ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*** បានអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ ចូលជួបសំណេះសំណាល សួរសុខទុក្ខ ពិភាក្សាការងារ និងសម្តែងការគួរសម ចំនួន៦លើក នៅវិមានសាមគ្គីភាព និងវិមាន៧មករា រួមមាន៖
    - **ឯកឧត្តម** Buakeo Phumvongsay ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
    - **ឯកឧត្តម** Santo Darmosumarto ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌូណេស៊ី។
    - **ឯកឧត្តម** Kim Chang-yong ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ។
    - **ឯកឧត្តម** Mohammed Ismaeil A. Dahlwy ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត។
    - **ឯកឧត្តម** Addrzej Duda អតីតប្រធានាធិបតីនៃសាធារណរដ្ឋប៉ូឡូញ និង
    - បងប្អូនវីរកងទ័ពទាំង១៨នាក់ និងក្រុមគ្រួសារ។
  - ❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**
    - **បេសកកម្មក្រៅប្រទេស៖** បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យ និងតាមដានប្រជាធិបតេយ្យ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងប៉ូដហ្គោរីកានៃសាធារណរដ្ឋម៉ុងតេណេហ្គ្រោ។

❖ **ឯកឧត្តម ងី ច័ន្ទផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតសភាតំបន់អាស៊ីលើកទី១៦ (16th APA Plenary Session) នៅទីក្រុងម៉ាណាម៉ា ព្រះរាជាណាចក្របារ៉ែន។

❖ **សម្តេចព្រះរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងជាតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសម្ពោធឈ្មោះសួនច្បារ **នរោត្តម សីហនុ** នៅសាធារណរដ្ឋបារាំង។

❖ **ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញទទួលអំណោយមនុស្សធម៌លើកទី១៥ និងលើកទី១៦ របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ រួមមាន ឱសថ សម្ភារវេជ្ជសាស្ត្រ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃ នៅវិមានព្រឹទ្ធសភា និង

❖ សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី ការត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង ឆ្នាំ២០២៦ នៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសភាជាតិកម្ពុជានៃសភាប្រើភាសាបារាំង នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសំណេះសំណាល សួរសុខទុក្ខ ពិភាក្សាការងារ និងសម្តែងការគួរសម ជាមួយភ្ញៀវជាតិ-អន្តរជាតិ នៅវិមានសាមគ្គីភាព និងវិមាន៧មករា ចំនួន៥លើក។
- បានអញ្ជើញចូលរួមទិវាបុណ្យជាតិអូស្ត្រាលី (Australia Day 2026) នៅស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា។
- បានអញ្ជើញចូលរួមខួបអនុស្សាវរីយ៍លើកទី៧៨ នៃទិវាបុណ្យឯករាជ្យជាតិនៃសហភាពសហព័ន្ធមីយ៉ាន់ម៉ា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។
- បានទទួលជួបពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិ ចំនួន២លើក រួមមាន៖ **ឯកឧត្តម** Marcos dos Reis da Costa ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និង**ឯកឧត្តម** Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថានប្រចាំកម្ពុជា ដើម្បីផ្លាស់ប្តូរយោបល់លើការពង្រឹងកិច្ចសហប្រតិបត្តិការនានា ដែលជាផលប្រយោជន៍រួមរវាងស្ថាប័នទាំងពីរ នៅបន្ទប់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។
- បានចូលរួមកិច្ចប្រជុំត្រៀមលក្ខណៈរៀបចំបដិសណ្ឋារកិច្ច និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និង

- បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមរៀបចំទទួលដំណើរទស្សនកិច្ចផ្លូវការរបស់ **ឯកឧត្តម** ស៊ីយ៉េដ យូសាហ្វេ រ៉ាសា ហ្គីឡានី (Syed Yusuf Raza Gillani) ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន នៅព្រះរាជាណាចក្រកម្ពុជា។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញពិនិត្យទីកន្លែង និងការសាកល្បងក្រុមកងកិត្តិយសត្រៃទ័ព សម្រាប់ទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភា។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជូនដំណើរ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យ និងតាមដានប្រជាធិបតេយ្យ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងប៉ូដហ្គោរីកា សាធារណរដ្ឋម៉ុងតេណេហ្គ្រោ នៅអាកាសយានដ្ឋានអន្តរជាតិតេជោ និង

❖ **ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសំណេះសំណាល សួរសុខទុក្ខ ពិភាក្សាការងារ និងសម្តែងការគួរសម ជាមួយភ្ញៀវជាតិ-អន្តរជាតិ នៅវិមានសាមគ្គីភាព និងវិមាន៧មករា ចំនួន៥លើក។

- បានសហការ និងទាក់ទងជាមួយមជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ (CFRD) បណ្ណសារដ្ឋានជាតិ-អន្តរជាតិ និងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេសនានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៤.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំចង្អៀតថ្នាក់ដឹកនាំ និងក្រុមការងារអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ស្តីពី ការរៀបចំពិធីសូត្រមន្ត និងចម្រើនព្រះបរិត្ត វិមានសាមគ្គីភាព និងការជ្រើសរើសមន្ត្រីថែទាំ និងផ្តល់សេវាអនាម័យ នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភា។
  - បានជួបប្រជុំជាមួយ **អ្នកឧកញ៉ាភក្តីព្រះស្តេច ហេង គឹមគុណា** ចាងហ្វាង ធម្មការ និងសាសនា ព្រះបរមរាជវាំង ដើម្បីត្រៀមរៀបចំពិធីក្រុងពាលី និងចម្រើនព្រះបរិត្តឡើងអគារថ្មីនៃព្រឹទ្ធសភា និង

- បានអញ្ជើញរៀបចំពិធីក្រុងពាលីបួងសួង សុំសេចក្តីសុខ សេចក្តីចម្រើន សុំការអនុញ្ញាត ដំឡើងទីសក្ការៈបូជាពានទេវតាថ្មី ថ្វាយដល់ទសបារមី វត្ថុស័ក្តិសិទ្ធិ ម្ចាស់ទឹក ម្ចាស់ដី ដែលថែរក្សាលើទីទឹកដី ជ័យភូមិ អគារវិមានសាមគ្គីភាពនៃព្រឹទ្ធសភា។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក បូរ៉ា ឯកឧត្តម ឡោក ឆាយ** និង**ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីក្រុងពាលី និងចម្រើនព្រះបរិត្តតាមបែបទំនៀមទម្លាប់ប្រពៃណីព្រះពុទ្ធសាសនា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដើម្បីសុំសេចក្តីសុខ សេចក្តីចម្រុងចម្រើនឡើងអគារថ្មី "វិមានសាមគ្គីភាព" នៃព្រឹទ្ធសភា។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា៖
  - បានអញ្ជើញអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញត្រួតពិនិត្យអគារថ្មីនៃព្រឹទ្ធសភា ដែលគ្រោងសម្ពោធក្នុងពេលខាងមុខ។
  - បានអញ្ជើញអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញត្រួតពិនិត្យការរៀបចំទីកន្លែងបំពេញការងារ នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភា។
  - បានអញ្ជើញអម **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញត្រួតពិនិត្យការរៀបចំទីកន្លែងបំពេញការងារ នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភា និង
  - បានអញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

- **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញប្រគល់-ទទួលម៉ាស៊ីនស្កេនចំនួន៣គ្រឿង ពីក្រុមហ៊ុន PRIMEX INTERNATIONAL CO.,LTD នៅវិមានព្រឹទ្ធសភា។

- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំប្រជុំការងារជាមួយក្រុមសន្តិសុខ នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភា។

- **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមការងារបច្ចេកទេសសាងសង់អគារ បានអញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃការបញ្ចប់សាងសង់ និងការតុបតែងខាងក្នុងអគារថ្មីនៃព្រឹទ្ធសភា មុននឹងរៀបចំពិធីសម្ពោធជាផ្លូវការនាពេលខាងមុខ នៅអគារវិមានសាមគ្គីភាពនៃព្រឹទ្ធសភា។

- **ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា៖
  - បានជួបប្រជុំជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ, ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានស្រាវជ្រាវ, ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងថ្នាក់ដឹកនាំអគ្គាធិការដ្ឋាន ព្រមទាំងជួបពិភាក្សាការងារតាមទូរស័ព្ទជាមួយថ្នាក់ដឹកនាំអង្គភាពសវនកម្មផ្ទៃក្នុង, ថ្នាក់ដឹកនាំអង្គភាពលទ្ធកម្ម, ថ្នាក់ដឹកនាំលេខាធិការដ្ឋានសមាគមសង្គហៈមន្ត្រីរាជការ និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីឈ្វេងយល់អំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ។

## ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

- បានស្នើសុំបុរេប្រទាន និងឥណទានថវិកា ចំនួន៣បុរេប្រទាន៖
  - សម្រាប់ការចំណាយបេសកកម្មក្រៅប្រទេស នៅទីក្រុងប៉ូដហ្គោរីកា នៃសាធារណរដ្ឋម៉ុងតេណេហ្គ្រោ។
  - សម្រាប់ទិញរថយន្តជូន **ឯកឧត្តម ឈឺវ យីស៊ាង** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និង
  - សម្រាប់ការរៀបចំក្រុង៣លី ចម្រើនព្រះបរិត្ត និងពិធីសម្ពោធអគារវិមានសាមគ្គីភាពនៃព្រឹទ្ធសភា។
- បានបង្វែរប្រាក់បង់វិភាគទានហានិភ័យការងារ និងភាគទានថែទាំសុខភាព ជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៦។
- បានបោះផ្សាយអាណត្តិ និងចុះប្រព័ន្ធ FMIS ជំពូក ៦០, ៦១, ៦២ និង៦៤ សម្រាប់ត្រីមាសទី១ ឆ្នាំ២០២៦។
- បានបង់ប្រាក់សំណៃសចំណាយប្រចាំខែមករា ឆ្នាំ២០២៦ ទៅធនាគារជាតិនៃកម្ពុជារួចរាល់។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែមករា ឆ្នាំ២០២៦ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែមករា ឆ្នាំ២០២៦ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤៩សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន៧១សំណើ។

- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣៧សំណើ។
- បានថតចម្លងឯកសារ ចំនួន៥,៤១៣ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន៨៤,៩១៣សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន ១១៦លើក ស្មើនឹង២២៣នាក់។
- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២១លើក។
- បានទទួលលិខិតចូល ចំនួន១,៣៥៤ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៥៥៦ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣៩ច្បាប់ ស្មើនឹង១១៦នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៨ច្បាប់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមាន៖
  - បានរៀបចំសួនចិញ្ចើមផ្លូវខាងមុខព្រឹទ្ធសភា។
  - បានគាស់ផើងដើមជ្រៃ មកដាំនៅអគារវិមានសាមគ្គីភាព។
  - បានជួសផ្កាកេសរកូល នៅមុខខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា។
  - បានដាំដើមត្នោតវិល នៅសួនច្បារជាប់គណៈកម្មការទី១០ព្រឹទ្ធសភា។
  - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១០លើក។
  - បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា និង
  - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានបន្តសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេសវិមានព្រឹទ្ធសភា។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ប្រចាំខែមករា ឆ្នាំ២០២៦ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖
  - មន្ត្រីរាជការក្របខណ្ឌ ចំនួន៧២០នាក់ (ស្រី២៩១) ក្នុងនោះមន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់, មន្ត្រីរាជការស្ថិតនៅក្រៅក្របខណ្ឌដើម ចំនួន៦នាក់, មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៣នាក់ និង
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៩២នាក់ (ស្រី៣៦នាក់)។
- បានធ្វើសេចក្តីសម្រេច ចំនួន៥ច្បាប់ និងលិខិតបង្គាប់ការ ចំនួន១ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៨ច្បាប់។

- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែមករា ឆ្នាំ២០២៦។
- បានបើកវគ្គបណ្តុះបណ្តាលក្នុងស្ថាប័នព្រឹទ្ធសភា ចំនួន១វគ្គ ស្តីពី វិធីសាស្ត្រសរសេរសុន្ទរកថា បទអន្តរាគមន៍ សេចក្តីថ្លែងការណ៍ និងជំនួយស្មារតី មានសិក្ខាកាមចូលរួម ចំនួន៥៣នាក់។
- បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំធ្វើប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនួយការថ្នាក់ដឹកនាំ ចំនួន១១៤នាក់។
- បានបូកសរុបទិន្នន័យវគ្គបណ្តុះបណ្តាល សិក្ខាសាលា តាមជំនាញ តាមវិស័យ ក្នុងរយៈពេល២ឆ្នាំ (២០២៤-២០២៥)។
- បានរៀបចំវគ្គបណ្តុះបណ្តាលក្នុងស្ថាប័នព្រឹទ្ធសភា ស្តីពី វិធីសាស្ត្រសរសេរសុន្ទរកថា បទអន្តរាគមន៍ សេចក្តីថ្លែងការណ៍ និងជំនួយស្មារតី មានសិក្ខាកាម ចំនួន៥៣នាក់។
- ការងារជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមានៈ
  - បានជួសជុលហោជាង នៅសាលប្រជុំពេញអង្គ និងសាលរង់ចាំអគារក្រហមខាងលិច-កើត។
  - បានរៀបចំបន្ទប់ជូន ឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានស្រាវជ្រាវ។
  - បានខាត់ លាបបង្គោលភ្លើងថ្មីអមសងខាងផ្លូវពីច្រកចេញ-ចូល P1 ដល់មុខអគារក្រហម និងគូសចំណតរថយន្ត នៅក្រោមដើមជ្រៃ និងអគារ F។
  - បានបំពាក់ឆត្រ និងជំបងពិល ជូនអង្គភាពការពារព្រឹទ្ធសភា នៅច្រកចេញ-ចូល P3 និង
  - បានបំពាក់កញ្ចក់សុវត្ថិភាពតាមកែងផ្លូវ។
- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្ត កំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន១០៣គ្រឿង/លើក។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៦ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៦ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៦។

## ៤.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន២៦ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានរៀបចំឯកសារជំនួយស្មារតីសម្រាប់៖
    - គណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន៣លើក។
    - សម័យប្រជុំលើកទី៤ និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន២លើក។
    - លេខាធិការសម័យប្រជុំ ចំនួន២លើក។
    - ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៥លើក និង
    - គណៈកម្មការបោះឆ្នោត ចំនួន១លើក។
- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៦លើក។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និងរៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៩៥លើក និង
- បានផ្ទៀងផ្ទាត់ សម្រួលបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប២ឆ្នាំ ចប់អាណត្តិ ឬលាលែងពីមុខតំណែង ចំនួន១១៤នាក់។

## ៤.៤-ការងារស្រាវជ្រាវ៖

- បានរៀបចំឯកសារស្រាវជ្រាវ និងឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន១ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ។
- បានសិក្សាស្រាវជ្រាវអំពី៖
    - បទពិសោធន៍កម្ពុជាក្នុងការដោះមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងទិដ្ឋភាពសេដ្ឋកិច្ច និងការកសាងជីវភាពប្រជាជនតាមតំបន់ព្រំដែន។
    - ស្ថិតិទេសចរណ៍ប្រចាំខែ ឆ្នាំ២០២៥។
    - ការប្រមូលចំណូលមិនមែនសារពើពន្ធរបស់អាកាសចរស៊ីវិល និង
    - ការប្រមូលចំណូលពន្ធប្រចាំត្រីមាសទី៣ ឆ្នាំ២០២៥។
- បានសិក្សាស្រាវជ្រាវ និងតាមដាន៖
    - វឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា និង
    - របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា និងព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា។
- បានតាមដានការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៧ និងការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។
- បានតាមដាន និងចងក្រង៖

- ឯកសារគោលនយោបាយជាតិស្តីពី ក្របខណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និង
- ឯកសារយុទ្ធសាស្ត្រជាតិស្តីពី ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥។

- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន២០៧ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ៥៨-៦៤ ឆ្នាំ២០២៤)។

**៤.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៤លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន១,៧៨០លើក។
- បានបញ្ចូល និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២២៩លើក។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៣លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខាងមុខព្រឹទ្ធសភា ចំនួន៨លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៦។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន១៤១គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៣៦លើក។
- បានរៀបចំបញ្ចូលឯកសារ សៀវភៅជា E-Book លើផ្នែកច្បាប់ និងសៀវភៅដែលទាញចេញពីគេឡេក្រាមរបស់បណ្ណាល័យនានា ក្នុងគេហទំព័រ www.elibrary.senate.gov.kh ចំនួន១០ក្បាល និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ថែងរក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបាន៖
  - រៀបចំឯកសាររបស់នាយកដ្ឋានរដ្ឋបាល ឆ្នាំ១៩៨៩-១៩៩៩ ចំនួន១៤៥សំណុំលិខិត និង

- ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន ៥១សំណុំ។

**៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៣៨លើក។
- បានរៀបចំសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ និងលិខិតរំលែកទុក្ខ របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន ឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ព្រមទាំងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា ចំនួន ៧លិខិត។
- បានរៀបចំលិខិតឆ្លើយតប កំណត់ទូត និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៣ច្បាប់/លើក។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៩ច្បាប់។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនផ្លូវការជូនថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនួយការថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន៦រូប និង
- បានតុបតែងលម្អ និងដាក់តាំងប៉ាណូ នៅខាងមុខស្ថាប័នព្រឹទ្ធសភា ក្នុងឱកាសនៃពិធីបុណ្យជាតិ ចំនួន២លើក។

**៤.៧-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៦ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែមករា ឆ្នាំ២០២៦។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែមករា ឆ្នាំ២០២៦ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៤០លើក ប្រចាំសប្តាហ៍ ចំនួន ៤លើក និងប្រចាំខែមករា ឆ្នាំ២០២៦ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។

- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និង សណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា របស់រាជរដ្ឋាភិបាលក្នុងរយៈពេលវិស្សមកាល៣ខែ ចាប់ពីថ្ងៃទី៧ ខែមករា ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖
    - អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ និង
    - អញ្ជើញចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ត្រៀមផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា រួមមាន៖
    - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ត្រៀមចុះជួបសំណេះសំណាលជាមួយអង្គបោះឆ្នោត នៅខណ្ឌដូនពេញ ខណ្ឌចំការមន ខណ្ឌទួលគោក ខណ្ឌឫស្សីកែវ និងខណ្ឌច្បារអំពៅ។
    - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២៖

      ១/ ត្រៀមចុះជួបសំណេះសំណាលជាមួយថ្នាក់ក្រុង ស្រុក ដើម្បីផ្សព្វផ្សាយសភាពការណ៍ប្រទេសជាតិ និងសមិទ្ធផលនានា ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីរាជការ ប្រជាពលរដ្ឋ តាមដានវឌ្ឍនភាពលើបញ្ហាប្រឈម និងសំណូមពររបស់ប្រឹក្សាឃុំ សង្កាត់ នៅខេត្តត្បូងឃ្មុំ និង

      ២/ ត្រៀមចុះជួបសំណេះសំណាល និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំង ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
    - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ត្រៀមចុះជួបសំណេះសំណាល និងបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងស្រុក ក្រុងនៃខេត្តកណ្តាល។
    - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ទី៥ និងទី៧ ត្រៀមចុះជួបសំណេះសំណាល

ជាមួយថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល នៅខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ និងខេត្តព្រះសីហនុ និង

- ក្រុមសមាជិកាព្រឹទ្ធសភា ត្រៀមចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារឆ្នាំ២០២៥ តម្រូវការ ការអនុវត្តគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រ ផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៦ និងឆ្លុះបញ្ចាំងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឃុំ សង្កាត់ ឆ្នាំ២០២២-២០២៧ នៅខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។

- ត្រៀមរៀបចំជូនសមាជិក សមាជិកា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមពិធីបុណ្យមាឃបូជា នៅព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និងនិស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជាប្រធានព្រឹទ្ធសភា នៅប្រទេសម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋអាស៊ែបៃហ្សង់។
- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមមហាសន្និបាត IPU លើកទី១៥២ នៅសាធារណរដ្ឋតួកគីយ៉េ។
- ត្រៀមទទួលដំណើរៈ
  - ទស្សនកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម នៅព្រះរាជាណាចក្រកម្ពុជា និង
  - ទស្សនកិច្ចរបស់ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន នៅព្រះរាជាណាចក្រកម្ពុជា។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិ ជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមរៀបចំពិធីសម្ពោធជាផ្លូវការអគារថ្មីនៃព្រឹទ្ធសភា។
- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី វគ្គទំនាក់ទំនងអន្តរជាតិ វគ្គសរសេររបាយការណ៍ និងកំណត់ហេតុប្រជុំ។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថាន

អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។

- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

ក្នុងខែមករា ឆ្នាំ២០២៦ ព្រឹទ្ធសភា បានបំពេញភារកិច្ច និងមុខងារសំខាន់ៗគ្រប់វិស័យដោយសម្រេចបានលទ្ធផលល្អប្រសើរ ទាំងមុខងារនីតិកម្ម មុខងារតំណាង មុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន ស្របតាមផែនការ។

ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាគាំទ្រប្រកបដោយប្រសិទ្ធភាពជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងបានយកចិត្តទុកដាក់លើការងាររដ្ឋបាល បច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ អនាម័យ បរិស្ថាន និងសន្តិសុខស្ថាប័ន បានល្អប្រសើរជាបន្តបន្ទាប់។

សម្រាប់ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភានឹងបន្តខិតខំអនុវត្តភារកិច្ចតាមផែនការដែលបានកំណត់ ដោយផ្តោតលើការគាំទ្រមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ ការចុះមូលដ្ឋានរបស់ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាក្នុងអំឡុងពេលវិស្សមកាល ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការអភិវឌ្ឍស្ថាប័ន ឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

ជារួម អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្តេជ្ញាបន្តលើកកម្ពស់វិន័យ ប្រសិទ្ធភាព ស្មារតីទទួលខុសត្រូវ និងសាមគ្គីភាពក្នុងការបំពេញភារកិច្ច ដើម្បីរួមចំណែកលើកកម្ពស់កិត្យានុភាព និងប្រសិទ្ធភាពការងាររបស់ព្រឹទ្ធសភា។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២៦

**អគ្គលេខាធិការ**

**ឡាយ សំកុល**